# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

៚៚៚ 🕮 ៚៚៚

**សាលាដំបូងខេត្តស្វាយរៀង**

សំណុំរឿងព្រហ្មទណ្ឌលេខ ០៦

ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣

សំណុំរឿងជំនុំជម្រះលេខ ១១០

ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៣

សាលក្រមព្រហ្មទណ្ឌលេខ ១០៩ “ក”

ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តស្វាយរៀង

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ និងប្រកាសសាលក្រមនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ នៅសាលាដំបូងខេត្តស្វាយរៀង ដោយមានសមាសភាពដូចតទៅ៖

### ចៅក្រមជំនុំជម្រះ

ឯកឧត្តម [redacted] ជាចៅក្រមជំនុំជម្រះ

លោក [redacted] ជាព្រះរាជអាជ្ញារង

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ជាក្រឡាបញ្ជីសាលាដំបូង

**ដើម្បីជំនុំជម្រះ** សំណុំរឿងព្រហ្មទណ្ឌលេខ ០៦ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទដូចខាងក្រោម៖

១/.ឈ្មោះ [redacted] យូជៀង ([redacted] YUCHIA) ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិចិន មុខរបរគ្រប់គ្រងហាងម៉ាស្សាជីងអ៊ី ទីកន្លែងកំណើត [redacted] ចិនតៃវ៉ាន់ ទីលំនៅបច្ចុប្បន្នស្នាក់នៅបន្ទប់ជួលលេខ ៤០២ ស្ថិតក្នុងភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted] ជីនម៉ូ “រស់” ម្តាយឈ្មោះ [redacted] ស៊ីយ៉ុ “រស់” នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ (ក្នុងឃុំ)

- ដីកាបង្គាប់ឱ្យឃុំខ្លួនជាបណ្តោះអាសន្នលេខ ១៨ បគ.ដល/២៣ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២៣។

ពីបទ៖ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៤, មាត្រា ៤៨ កថាខណ្ឌទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២/.ឈ្មោះ [redacted] ស៊ីងហៅ ([redacted] SENGHOV) ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិចិន មុខរបរចុងភៅ ទីកន្លែងកំណើតនៅ [redacted] ប្រទេសចិនតៃវ៉ាន់ ទីលំនៅបច្ចុប្បន្នស្នាក់នៅបន្ទប់ជួលលេខ ៤១២ ស្ថិតក្នុងភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted] ហ្វូទី “រស់” ម្តាយឈ្មោះ [redacted] ព័រយាន “រស់” នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន។ (ក្រៅឃុំ)

- ដីកាបង្គាប់ឱ្យដោះលែងលេខ ៣៤ បគ.ដល/២៣ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣។



Scanned with CamScanner

ពីបទ៖ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបារិតកណ្តាល សង្កាត់បារិត ក្រុងបារិត ខេត្តស្វាយរៀង កាលពីថ្ងៃទី០២ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ដោយមានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] យូជៀង [redacted] YUCHIA)។

- បានឃើញ ដីកាដំណោះស្រាយលេខ ៩៦៤ “ង” ដជ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣។

- បានឃើញ ដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ ១១៣ ជ.ស.រ/២៣ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តស្វាយរៀង។

## អង្គហេតុមានដូចតទៅ៖

កាលពីថ្ងៃទី០២ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ២១និង៣០ នាទី កម្លាំងជំនាញអធិការដ្ឋាននគរបាលក្រុងបារិត បានទទួលពត៌មានពីប្រជាពលរដ្ឋ ដោយបានចុះស្រាវជ្រាវដល់ទីតាំងកើតហេតុស្ថិតនៅចំណុចហាងម៉ាស្សាយីហោជឹងអ៊ី ស្ថិតនៅភូមិបារិតកណ្តាល សង្កាត់បារិត ក្រុងបារិត ខេត្តស្វាយរៀង និងឈានដល់ការឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted] ស៊ីងហៅ [redacted] SENGHOV) ពាក់ព័ន្ធនឹងករណី ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងឈ្មោះ [redacted] យូជៀង [redacted] YUCHIA) ពាក់ព័ន្ធនឹងករណី រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន រួមទាំងដកហូតវត្ថុចាប់យកមួយចំនួន។ បន្ទាប់មកក្រោយពីធ្វើការសួរចម្លើយចម្លើយជនត្រូវចោទខាងលើ និងបានឆ្លើយសារភាពនូវអំពើល្មើសរបស់ខ្លួន រួចសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនមកតុលាការចាត់ការតាមនីតិវិធីច្បាប់។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] យូជៀង [redacted] YUCHIA) បានឆ្លើយថា៖ សមត្ថកិច្ចឃាត់ខ្លួនកាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៣។ ខ្លួនស្គាល់ឈ្មោះ [redacted] ស៊ីងហៅ។ ខ្លួន និងឈ្មោះ [redacted] ស៊ីងហៅ មិនមែនជាអ្នកស្នាក់នៅបន្ទប់ជាមួយគ្នាទេ។ ខ្លួនស្នាក់នៅជាន់ទី៤ បន្ទប់លេខ៤០២ នៃអគារស្នាក់នៅក្នុងហាងម៉ាស្សាយីហោ ជឹងអ៊ី ដោយបច្ចុប្បន្នគឺខ្លួនស្នាក់នៅតែម្នាក់ឯងទេ។ ខ្លួនមានការងារជាអ្នកគ្រប់គ្រងហាងម៉ាស្សា និងជាកន្លែងដែលខ្លួនស្នាក់នៅនេះតែម្តង។ ពីមុនមកបន្ទប់ដែលខ្លួនស្នាក់នៅ គឺខ្លួនស្នាក់នៅជាមួយជនជាតិវៀតណាមម្នាក់ ឈ្មោះ ទុង លុះស្នាក់នៅជាមួយគ្នាបានរយៈពេលជាងមួយខែ ជនជាតិវៀតណាមនោះក៏ឈប់ស្នាក់នៅ ហើយត្រឡប់ទៅប្រទេសវៀតណាមវិញ។ មូលហេតុដែលឈ្មោះ ទុង ឈប់ស្នាក់នៅប្រទេសកម្ពុជា ទៅប្រទេសវៀតណាមវិញ ដោយសារតែឈ្មោះ ទុង មានបញ្ហាគ្រួសារ ក្រោយៗមកទៀតខ្លួនក៏ទាក់ទងឈ្មោះ ទុង នេះលែងបានតែម្តង។ ខ្លួនមិនស្គាល់អ្នកណានោះទេនៅប្រទេសកម្ពុជា ហើយខ្លួនមកប្រទេសកម្ពុជា គឺគោលបំណងមករកការងារធ្វើ ហើយក៏ត្រូវបានមិត្តភក្តិម្នាក់ជាជនជាតិតៃវ៉ាន់ជាអ្នកណែនាំការងារនេះឱ្យធ្វើ។ បារីអេឡិចត្រូនិច ជារបស់ខ្លួន ផ្ញើមកពីតៃវ៉ាន់ ខ្លួនចេះប្រើប្រាស់សម្រាប់ផ្តាច់បារី។ ខ្លួនទើបតែចេះប្រើប្រាស់ថ្នាំញៀននៅពេលថ្មីៗនេះតែប៉ុណ្ណោះ គឺប្រើប្រាស់តែម្នាក់ឯង



Scanned with CamScanner

នៅក្នុងបន្ទប់ស្នាក់នៅរបស់ខ្លួន។ ថ្នាំញៀនដែលសមត្ថកិច្ចឆែកឆេរក្នុងបន្ទប់ស្នាក់នៅរបស់ខ្លួន និងដកហូតបាន ខ្លួនទទួលស្គាល់ថាជារបស់ខ្លួន ប៉ុន្តែថ្នាំញៀនទាំងនោះ គឺខ្លួនមិនមែនជាអ្នកទំនាក់ទំនងទិញនោះទេ ថ្នាំញៀននោះគឺឈ្មោះ ទុង ជនជាតិវៀតណាម ដែលស្នាក់នៅជាមួយខ្លួនជាអ្នកទំនាក់ទំនងទិញ ខ្លួនមិនបានដឹងថាឈ្មោះ ទុង ទិញមកពីណានោះទេ។ ថ្នាំញៀនទាំងនោះ ខ្លួនបានខលសួរឈ្មោះ ទុង ទើបឈ្មោះ ទុង បានប្រាប់ខ្លួនថា មានតម្លៃ ១,០០០ ដុល្លារអាមេរិក ប៉ុន្តែខ្លួនមិនទាន់បានវេរលុយឱ្យឈ្មោះ ទុង នោះទេ ខ្លួនមានបំណងទុកថ្នាំញៀនទាំងនោះសម្រាប់ប្រើប្រាស់ ទើបមិនបានរាយការណ៍ប្រាប់សមត្ថកិច្ច។ នៅថ្ងៃដែលសមត្ថកិច្ចឃាត់ខ្លួន គឺដោយសារតែមានជនជាតិវៀតណាមប្រើប្រាស់អាវុធនៅក្លោងទ្វារធំខាងមុខហាងម៉ាស្សា ទើបបានជាឈានដល់ការឃាត់ខ្លួន និងការឆែកឆេរបន្ទប់ស្នាក់របស់ខ្លួន។

- តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីងហៅ (CHI SENGHOV) នៅដំណាក់កាលចៅក្រមស៊ើបសួរបានឆ្លើយថា៖ ខ្លួនចេះប្រើប្រាស់ថ្នាំញៀន នៅអំឡុងខែមីនា ឆ្នាំ២០២១។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនដោយខ្លួនឯង ចំពោះថ្នាំញៀនគឺខ្លួនទិញពីក្នុងខារ៉ាអូខេប៉ៅអ៊ី ស្ថិតនៅក្រុងបាវិត ខេត្តស្វាយរៀង។ ថ្នាំញៀនខ្លួនទិញម្តងៗ ក្នុង ០១កញ្ចប់ តម្លៃ ៥០ដុល្លារអាមេរិក ទិញយកមកទុកសម្រាប់តែប្រើប្រាស់ម្នាក់ឯងតែប៉ុណ្ណោះ ខ្លួនពុំធ្លាប់បានចែកចាយឱ្យអ្នកណាផ្សេងទេ។ នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៣ ដែលសមត្ថកិច្ចបានចុះប្រតិបត្តិការបង្ក្រាបករណីហិង្សានោះ គឺខ្លួនមិនបានចូលរួមប្រព្រឹត្តអំពើហិង្សានោះទេ។ ពេលសមត្ថកិច្ចឃាត់ខ្លួនដកហូតបានសម្ភារៈវត្ថុតាងរួមមាន ទូរសព្ទដៃចំនួន ០២គ្រឿង, លិខិតឆ្លងដែន ចំនួន០៤, កាបូបដៃ ចំនួន០១, បារីអេឡិចត្រូនិច ចំនួន ០២ដើម និងកាតចាក់វ៉ាក់សាំងកូវីដ ចំនួន ០១សន្លឹក។

- លោក [redacted] ជាមន្ត្រីនគរបាលយុត្តិធម៌បានឆ្លើយបំភ្លឺថា៖ កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ០៩ និង ៣០ នាទី កម្លាំងអធិការដ្ឋាននគរបាលក្រុងបាវិត បានទទួលពត៌មានថា នៅយប់ថ្ងៃទី០២ ខែមករា ឆ្នាំ២០២៣ ពាក់ព័ន្ធនឹងករណី ផ្ទុះអាវុធ ស្ថិតនៅហាងម៉ាស្សាយីហោជឹងអ៊ី ស្ថិតនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង ហើយបានរាយការណ៍ជូនលោកព្រះរាជអាជ្ញារង ដើម្បីដឹកនាំកម្លាំងចុះទៅពិនិត្យនៅទីតាំងកើតហេតុខាងលើ។ នៅពេលទៅដល់ក៏បានចូលពិនិត្យតាមបន្ទប់នីមួយៗនៃហាងម៉ាស្សាយីហោជឹងអ៊ី ហើយក្នុងប្រតិបត្តិការខាងកម្លាំងបានបិទបន្ទប់ចំនួន ០៥ រួមមាន បន្ទប់លេខ ៤០២, លេខ ៤១០, លេខ ៤១១, លេខ ៤១៣ និងបន្ទប់លេខ ៤១៥។ មូលហេតុដែលឈានទៅដល់ការបិទបន្ទប់ទាំងប្រាំនេះជាបណ្តោះអាសន្ន ដោយសារសង្ស័យពាក់ព័ន្ធនឹងករណីគ្រឿងញៀន ដោយតាមបន្ទប់នីមួយៗបានបន្សល់ទុកសម្ភារៈប្រើប្រាស់គ្រឿងញៀន ប៉ុន្តែពុំមានមនុស្សស្នាក់នៅទេ មានតែបន្ទប់លេខ ៤០២ គឺមានជនជាតិចិនឈ្មោះ [redacted] យូជៀង ស្នាក់នៅ ទើបសមត្ថកិច្ចបានឃាត់ខ្លួន និងដកហូតវត្ថុចាប់យក ហើយបានបញ្ជូនមកតុលាការចាត់ការតាមនីតិវិធី។

- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ក្រោយពីបានបញ្ចប់កិច្ចពិភាក្សាដេញដោលរួចមកឃើញថា ជនជាប់ចោទគឺពិតជាបានប្រព្រឹត្តនូវសកម្មភាពដូចអ្វីដែលតំណាងអយ្យការបានចោទប្រកាន់ប្រាកដមែន។ ហេតុដូច្នេះ ក្នុងនាមតំណាងអយ្យការសុំរក្សាបទចោទប្រកាន់ទៅលើជនជាប់ចោទ



Scanned with CamScanner

តាមដីកាសន្និដ្ឋានស្ថាពរដដែល និងតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ១១១ អ.យ.ង ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ទុកជាបានការដដែល ហើយសូមចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] យូជៀង [redacted] YUCHIA) បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ កូនក្តីរបស់ខ្លួនឆ្លើយសារភាពទទួលស្គាល់នូវកំហុសរបស់ខ្លួនថា ពិតជាបានទិញថ្នាំញៀនពីឈ្មោះ ទុង ជនជាតិវៀតណាម ទុកសម្រាប់ប្រើប្រាស់ប្រាកដមែន ប៉ុន្តែមិនមានគោលបំណងយកទៅធ្វើការចែកចាយដល់អ្នកដទៃឡើយ។ កូនក្តីរបស់ខ្លួនគឺគ្រាន់តែជាជនរងគ្រោះដែលបានផុងខ្លួនក្នុងការប្រើប្រាស់ថ្នាំញៀន តាមរយៈការអូសទាញពីមិត្តភក្តិតែប៉ុណ្ណោះ។ សូមបញ្ជាក់បន្ថែមថា កូនក្តីរបស់ខ្លួនចូលមកប្រទេសកម្ពុជាដោយស្របច្បាប់ គោលបំណងដើម្បីស្វែងរកការងារធ្វើ និងបានស្នាក់នៅបន្ទប់ជួលលេខ៤០២ ស្ថិតក្នុងភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង ហើយក៏រកបានការងារជាអ្នកគ្រប់គ្រងហាងម៉ាស្សាយីហោ ជីងអ៊ី ផងដែរ។ ក្រោយពីជាប់ពន្ធនាគាររយៈពេលជាង ០៥ខែកន្លងមកនេះ ឃើញថាកូនក្តីរបស់ខ្លួនមានការសោកស្តាយ និងភ្ញាក់រលឹកចំពោះទង្វើរបស់ខ្លួនដែលបានប្រព្រឹត្តនូវសកម្មភាពប្រើប្រាស់គ្រឿងញៀន ហេតុនេះខ្លួនស្នើសុំឱ្យតុលាការគប្បីពិនិត្យ និងពិចារណាសម្រេចផ្តល់នូវស្ថានសម្រាលទោស តាមមាត្រា ៩៣ និងមាត្រា ៩៤ និងស្នើសុំការព្យួរទោសតាមមាត្រា ១០៦ មាត្រា ១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ដល់កូនក្តីរបស់ខ្លួនផង ដើម្បីឱ្យកូនក្តីរបស់ខ្លួនមានឱកាសក្នុងការកែប្រែខ្លួន និងឆាប់បានវិលត្រឡប់ទៅស្រុកកំណើតមើលថែរក្សាឪពុកម្តាយវិញ។

- ជនជាប់ចោទឈ្មោះ [redacted] យូជៀង [redacted] YUCHIA) ធ្វើការសំណូមពរចុងក្រោយថា៖ សូមតុលាការមេត្តាសម្រេចបន្ធូរបន្ថយទោសដល់ខ្លួនផង ដើម្បីខ្លួនបានឆាប់ចេញទៅស្រុកកំណើតខ្លួន មើលថែឪពុកម្តាយវិញ ព្រោះខ្លួនបានដឹងពីកំហុសរបស់ខ្លួន និងសន្យាថានឹងប្រើប្រាស់គ្រឿងញៀនទៀតឡើយ។

- ក្រោយពីបានស្តាប់ចម្លើយ និងអំណានចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយបំភ្លឺរបស់មន្ត្រីនគរបាលយុត្តិធម៌
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ
- ក្រោយពីបានស្តាប់ជនជាប់ចោទធ្វើសំណូមពរជាសំដីចុងក្រោយ
- ក្រោយពីបានពិនិត្យលើភស្តុតាងនានា
- ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តស្វាយរៀង
## យល់ឃើញថា

- តាមដីកាដំណោះស្រាយលេខ ៩៦៤ "ង" ដង ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តស្វាយរៀង បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] យូជៀង [redacted] YUCHIA) ទៅជំនុំជម្រះពីបទ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិ



Scanned with CamScanner

បាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៤, មាត្រា ៤៨ កថាខណ្ឌទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ជនជាប់ចោទឈ្មោះ [redacted] ស៊ីងហៅ ([redacted] SENGHOV) ទៅជំនុំជម្រះពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី០២ ខែមករា ឆ្នាំ ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

- កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៣ នៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង ពិតជាមានអំពើ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] យូជៀង (LU YUCHIA) ប្រាកដមែន។

- កាលពីថ្ងៃទី០២ ខែមករា ឆ្នាំ២០២៣ នៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង ពិតជាមានអំពើ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] ស៊ីងហៅ ([redacted]SENGHOV) ប្រាកដមែន។

- តាមរបាយការណ៍លេខ ០៣ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង, ចម្លើយបំភ្លឺរបស់មន្ត្រីនគរបាលយុត្តិធម៌ និងតាមចម្លើយសារភាពរបស់ជនជាប់ចោទ អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] យូជៀង [redacted] YUCHIA) ពិតជាបានប្រព្រឹត្តអំពើដែលជាបទល្មើស រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលត្រូវផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី៤, មាត្រា ៤៨ កថាខណ្ឌទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ជនជាប់ចោទឈ្មោះ [redacted] ស៊ីងហៅ [redacted] SENGHOV) ពិតជាបានប្រព្រឹត្តអំពើដែលជាបទល្មើស ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

- សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ បានស្នើសុំឱ្យតុលាការពិចារណាសម្រេចផ្តន្ទាទោសជនជាប់ចោទតាមកំណត់ច្បាប់ ដូច្នេះតុលាការនឹងធ្វើការពិនិត្យ ពិចារណា។

- សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានស្នើសុំឱ្យតុលាការពិនិត្យ និងពិចារណាសម្រេចផ្តល់នូវស្ថានសម្រាលទោស ដល់ជនជាប់ចោទឈ្មោះ [redacted] យូជៀង [redacted] YUCHIA) តាមមាត្រា ៩៣ និងមាត្រា ៩៤ និងស្នើសុំការព្យួរទោសតាមមាត្រា ១០៦ មាត្រា ១០៧ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ឃើញថាការស្នើសុំនេះ មានភស្តុតាងជាសំអាងលើកយកមកបញ្ជាក់ត្រឹមត្រូវ រួមជាមួយនឹងចម្លើយសារភាពរបស់ជនជាប់ចោទ ក៏ដូចជាការពិនិត្យមើលទៅលើអង្គហេតុ និងភស្តុតាងជាឯកសារផ្សេងៗដែលមាននៅក្នុងសំណុំរឿង ដូច្នេះគប្បីតុលាការពិនិត្យ និងពិចារណាសម្រេចក្នុងការព្យួរទោសដល់ជនជាប់ចោទឈ្មោះ [redacted] យូជៀង [redacted] YUCHIA)។



Scanned with CamScanner

- តាមកំណត់ហេតុទទួលវត្ថុចាប់យក លេខ ០៨ អ.យ.ង ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តស្វាយរៀង វត្ថុតាងដែលដកហូតបានពី៖

ក.ជនជាប់ចោទឈ្មោះ [redacted] យូជៀង [redacted] YUCHIA) មាន៖ ថ្នាំកញ្ចប់ពណ៌ខ្មៅ ចំនួន ០៥កញ្ចប់ (រហែក ០១កញ្ចប់), ទូរសព្ទដៃម៉ាក IPhone14 Pro Max ពណ៌ស្វាយ ចំនួន ០១គ្រឿង, ទូរសព្ទដៃម៉ាក IPhone14 ពណ៌ទឹកសមុទ្រ ចំនួន ០១គ្រឿង, ទូរសព្ទដៃម៉ាក IPhone6s ពណ៌ស ចំនួន ០១គ្រឿង, កាបូបដៃចំនួន០១, កាតធនាគារចំនួន ០៧សន្លឹក, លិខិតឆ្លងដែនចំនួន ០១ក្បាល, បារីអេឡិចត្រូនិច ចំនួន ២៧ដើម, គ្រាប់កាំភ្លើងអាការ៤៧ ចំនួន ០២គ្រាប់, ប័ណ្ណសុខភាព ០១សន្លឹក, ប័ណ្ណការងារជនបរទេស ០១សន្លឹក, អត្តសញ្ញាណប័ណ្ណ ចិនតៃវ៉ាន់ ០២សន្លឹក, ប័ណ្ណបើកបរ ០២សន្លឹក និងស្រោមសំបុត្របិទជិតពណ៌គគីរ ចំនួន ០១។

ខ.ជនជាប់ចោទឈ្មោះ [redacted] ស៊ីងហៅ ([redacted] SENGHOV) មាន៖ ទូរសព្ទដៃម៉ាក IPhone13 mini ពណ៌ស ចំនួន ០១គ្រឿង, ទូរសព្ទដៃម៉ាក IPhone12 Pro ពណ៌ទឹកប៊ិច ចំនួន ០១គ្រឿង, លិខិតឆ្លងដែនជនជាតិវៀតណាម លេខ C 9417155 ចំនួន ០១ក្បាល, លិខិតឆ្លងដែនជនជាតិវៀតណាម លេខ K 0282634 ចំនួន ០១ក្បាល, លិខិតឆ្លងដែនជនជាតិវៀតណាម លេខ C 9804799 ចំនួន ០១ក្បាល, លិខិតឆ្លងដែនចិនតៃវ៉ាន់ លេខ 352037126 ចំនួន ០១ក្បាល, កាបូបដៃ ចំនួន០១, បារីអេឡិចត្រូនិច ចំនួន ០២ដើម និងកាតចាក់វ៉ាក់សាំងកូវីដ១៩ ចំនួន ០១សន្លឹក។

គប្បីតុលាការសម្រេចដោយផ្អែកតាមមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

- តាមកំណត់ហេតុបើក បិទ និងដកហូតសំណាកគ្រឿងញៀន ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តស្វាយរៀង ដែលដកហូតពីជនជាប់ចោទឈ្មោះ [redacted] យូជៀង [redacted] YUCHIA) មាន៖

ក.ម្សៅក្រាមពណ៌សថ្លា មានថ្នាំសុទ្ធទម្ងន់ ៩,១៤ក្រាម ហើយធ្វើការបែងចែកដោយដាក់ម្សៅក្រាមពណ៌សថ្លាចំនួន ០១កញ្ចប់ មានថ្នាំសុទ្ធទម្ងន់ ០,៦៥ក្រាម ដាក់ចូលទៅក្នុងស្រោមសំបុត្រពណ៌គគីរបិទជិតចំនួន០១ សម្រាប់បញ្ជូនទៅធ្វើកោសលវិច័យនៅអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។ ដាក់ម្សៅក្រាមពណ៌សថ្លាចំនួន ០១កញ្ចប់ មានថ្នាំសុទ្ធទម្ងន់ ១,០១ក្រាម ដាក់ចូលទៅក្នុងស្រោមសំបុត្រពណ៌គគីរបិទជិតចំនួន០១ សម្រាប់ទុកធ្វើប្រតិកោសលវិច័យ។ ដាក់ម្សៅក្រាមពណ៌សថ្លាចំនួន ០១កញ្ចប់ មានថ្នាំសុទ្ធទម្ងន់ ៧,៤៨ក្រាម ដាក់ចូលទៅក្នុងស្រោមសំបុត្រពណ៌គគីរបិទជិតចំនួន០១ ដើម្បីរក្សាទុក នៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តស្វាយរៀង។

ខ.ម្សៅម៉ត់ពណ៌ទឹកក្រូច មានសារធាតុសុទ្ធទម្ងន់ ១១៨,២៥ក្រាម ហើយធ្វើការបែងចែកម្សៅម៉ត់ពណ៌ទឹកក្រូច ជា ០៣កញ្ចប់ ដោយកញ្ចប់ទី១ មានថ្នាំសុទ្ធទម្ងន់ ៤,៦១ក្រាម កញ្ចប់ទី២ មានថ្នាំសុទ្ធទម្ងន់ ៤,៦១ក្រាម និងកញ្ចប់ទី៣ មានថ្នាំសុទ្ធទម្ងន់ ៤,៦៥ក្រាម ដាក់ចូលទៅក្នុងស្រោមសំបុត្រពណ៌គគីរបិទជិតចំនួន០១ សម្រាប់បញ្ជូនទៅធ្វើកោសលវិច័យនៅអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។ ដោយ



Scanned with CamScanner

ខ្សែកម្សៀម៉ែត់ពណ៌ទឹកក្រូចមានសារធាតុសុទ្ធនៅសល់ទម្ងន់ ១០៩,៣៨ក្រាម បានដាក់ចូលទៅក្នុងស្រោមសំបុត្រពណ៌គគីរបិទជិតចំនួន០១ ដើម្បីរក្សាទុកនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តស្វាយរៀង។

"ថ្លឹងដោយជញ្ជីងម៉ាក METTLER TOLEDO"

- តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៩០៣២៦/២៣ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ការសន្និដ្ឋាន៖

ក.សំណាកទី១ ជាគ្រឿងញៀនប្រភេទក្រាមម្សៅថ្លា ឈ្មោះ កេតាមីន ឋិតក្នុងតារាងទី៣ មាត្រា ៥ ចំណាត់ថ្នាក់គ្រឿងញៀន ដែលមានកម្រិតភាពសុទ្ធ ៦៣.៩៣% (ហុកសិបបី កណ្ដក់សញ្ញា សែសិបបី ភាគរយ) នៃទម្ងន់សរុប ៩,១៩ក្រាម ដូច្នេះបរិមាណសុទ្ធស្មើនឹង ៥,៧៩ក្រាម។

ខ.សំណាកទី២ ជាគ្រឿងញៀនប្រភេទម្សៅម៉ដ្ឋ ដែលមានផ្ទុកនូវសារធាតុញៀន ០២ (ពីរ) ប្រភេទគឺ ឈ្មោះ អឹម ឌេ អឹម អា ឋិតក្នុងតារាងទី១ មាត្រា ៥ ចំណាត់ថ្នាក់គ្រឿងញៀន ដែលមានកម្រិតភាពសុទ្ធ 0.១0% (សូន្យ កណ្ដក់សញ្ញា ដប់ ភាគរយ) នៃទម្ងន់សរុប ១១៨,២៥ក្រាម ដូច្នេះបរិមាណសុទ្ធស្មើនឹង 0,១១ក្រាម និងឈ្មោះ កេតាមីន ឋិតក្នុងតារាងទី៣ មាត្រា ៥ ចំណាត់ថ្នាក់គ្រឿងញៀន ដែលមានកម្រិតភាពសុទ្ធ 0.៨៥% (សូន្យ កណ្ដក់សញ្ញា ប៉ែតសិបប្រាំ ភាគរយ) នៃទម្ងន់សរុប ១១៨,២៥ក្រាម ដូច្នេះបរិមាណសុទ្ធស្មើនឹង ១,00ក្រាម។

- ជនជាប់ចោទឈ្មោះ [redacted] យូជៀង [redacted] YUCHIA) ពិតជាមានចេតនាប្រព្រឹត្តអំពើ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ហើយពេលប្រព្រឹត្តនោះជនជាប់ចោទមានស្មារតីគ្រប់គ្រាន់ក្នុងការយល់ដឹងនូវអំពើរបស់ខ្លួន។

- ជនជាប់ចោទឈ្មោះ [redacted] ស៊ីងហៅ ([redacted] SENGHOV) ពិតជាមានចេតនាប្រព្រឹត្តអំពើ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ហើយពេលប្រព្រឹត្តនោះជនជាប់ចោទមានស្មារតីគ្រប់គ្រាន់ក្នុងការយល់ដឹងនូវអំពើរបស់ខ្លួន។

- អំពើល្មើសដែលជនជាប់ចោទឈ្មោះ [redacted] យូជៀង [redacted] YUCHIA) ប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្ដាប់ធ្នាប់សង្គម និងប៉ះពាល់ដល់ច្បាប់របស់រដ្ឋ ដែលមានចែងក្នុងបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៤, មាត្រា ៤៨ កថាខណ្ឌទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

- អំពើល្មើសដែលជនជាប់ចោទឈ្មោះ [redacted] ស៊ីងហៅ ([redacted] SENGHOV) ធ្វើឱ្យប៉ះពាល់ដល់ សន្តិសុខសណ្ដាប់ធ្នាប់សង្គម និងប៉ះពាល់ដល់ច្បាប់របស់រដ្ឋ ដែលមានចែងក្នុងបញ្ញត្តិមាត្រា ៤៥ កថាខណ្ឌទី ១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

- តាមពាក្យសុំបើកបន្ទប់ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] ស្រីពៅ បានស្នើសុំបើកបន្ទប់លេខ ៤០២ ៤១០ ៤១១ ៤១៣ និង ៤១៥ នៃអាគារស្នាក់នៅ ដែលមានទីតាំងស្ថិតនៅភូមិបាវិតកណ្ដាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង វិញ តុលាការពិនិត្យឃើញថាការស្នើសុំនេះមិនប៉ះពាល់ដល់ផលប្រយោជន៍នៃនីតិវិធីនោះទេ ដូច្នេះតុលាការនឹងសម្រេចតាមការស្នើសុំខាងលើនេះ។



Scanned with CamScanner

- មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់អំពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] យូជៀង ([redacted] YUCHIA) ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិចិន ពីបទ៖ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៤, មាត្រា ៤៨ កថាខណ្ឌទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

- មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់អំពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ស៊ីងហៅ (CHI SENGHOV) ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិចិន ពីបទ៖ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី០២ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសលើជនជាប់ចោទ៖

ក.ឈ្មោះ [redacted] យូជៀង [redacted] YUCHIA) ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិចិន (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ០៣ (បី) ឆ្នាំ តែទោសនេះត្រូវអនុវត្តទោសពន្ធនាគារកំណត់ ០១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃឃុំខ្លួន រីឯទោសសល់ពីនេះត្រូវអនុវត្តទោសព្យួរ។

ពីបទ៖ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៤, មាត្រា ៤៨ កថាខណ្ឌទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ.ឈ្មោះ [redacted] ស៊ីងហៅ [redacted] SENGHOV) ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិចិន (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ០១ (មួយ) ឆ្នាំ តែទោសនេះត្រូវអនុវត្តទោសព្យួរទាំងអស់។

ពីបទ៖ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី០២ ខែមករា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-អនុញ្ញាតឱ្យបើកបន្ទប់លេខ ៤០២ ៤១០ ៤១១ ៤១៣ និង ៤១៥ នៃអាគារស្នាក់នៅ ដែលមានទីតាំងស្ថិតនៅភូមិបាវិតកណ្តាល សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះចូលស្ថាពរ។

៣-វត្ថុតាងរួមមាន៖

- ម្សៅក្រាមពណ៌សថ្លា មានថ្នាំសុទ្ធទម្ងន់ ៩,១៤ក្រាម ម្សៅម៉ត់ពណ៌ទឹកក្រូច មានសារធាតុសុទ្ធទម្ងន់ ១១៨,២៥ក្រាម ថ្នាំកញ្ចប់ពណ៌ខ្មៅ ចំនួន ០៥កញ្ចប់ (រហែក ០១កញ្ចប់), បារីអេឡិចត្រូនិច ចំនួន



Scanned with CamScanner

២៩ដើម និងគ្រាប់កាំភ្លើងអាការ៤៧ ចំនួន ០២គ្រាប់ **ត្រូវរឹបអូសបំផ្លាញចោល**។

- ទូរសព្ទដៃម៉ាក IPhone14 Pro Max ពណ៌ស្វាយ ចំនួន ០១គ្រឿង, ទូរសព្ទដៃម៉ាក IPhone14 ពណ៌ទឹកសមុទ្រ ចំនួន ០១គ្រឿង, ទូរសព្ទដៃម៉ាក IPhone6s ពណ៌ស ចំនួន ០១គ្រឿង, ទូរសព្ទដៃម៉ាក IPhone13 mini ពណ៌ស ចំនួន ០១គ្រឿង, ទូរសព្ទដៃម៉ាក IPhone12 Pro ពណ៌ទឹកប៊ិច ចំនួន ០១គ្រឿង, លិខិតឆ្លងដែនជនជាតិវៀតណាម លេខ C 9417155 ចំនួន ០១ក្បាល, លិខិតឆ្លងដែនជនជាតិវៀតណាម លេខ K 0282634 ចំនួន ០១ក្បាល, លិខិតឆ្លងដែនជនជាតិវៀតណាម លេខ C 9804799 ចំនួន ០១ក្បាល, លិខិតឆ្លងដែនចិនតៃវ៉ាន់ លេខ 352037126 ចំនួន ០១ក្បាល, លិខិតឆ្លងដែនចំនួន ០១ក្បាល, កាបូបដៃ ចំនួន០២, កាតធនាគារចំនួន ០៧សន្លឹក, ប័ណ្ណសុខភាព ០១សន្លឹក, ប័ណ្ណការងារជនបរទេស ០១សន្លឹក, អត្តសញ្ញាណប័ណ្ណ ចិនតៃវ៉ាន់ ០២សន្លឹក, ប័ណ្ណបើកបរ ០២សន្លឹក និងកាតចាក់វ៉ាក់សាំងកូវីដ១៩ ចំនួន ០១សន្លឹក **ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ**។

ផ្អែកតាមមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤-សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]យូជៀង (LU YUCHIA) និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted]ស៊ីងហៅ ([redacted] SENGHOV)។

“បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់”

**ក្រឡាបញ្ជី**
ហត្ថលេខា និងត្រា
[redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា
[redacted]

---

“បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម”
ថ្ងៃពុធ ១១រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ស្វាយរៀង, ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣
**ក្រឡាបញ្ជី**
[redacted]

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**
[redacted]



Scanned with CamScanner